# ការប្រាក់
# និងការប្រាក់យឺតយ៉ាវ

សន្និបាតវិស័យយុត្តិធម៌ ឆ្នាំ២០២៥

ថ្ងៃទី១២ ដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៥

# មាតិកា

- តាពចាំបាច់នៃប្រធានបទ
- ចំណោទបញ្ហាគតិយុត្ត
- ក្របខណ្ឌច្បាប់
- ការសន្និដ្ឋានរួម និងសំណើសុំការសម្រេច

# ១-ភាពចាំបាច់នៃប្រធានបទ

១-សំណុំរឿងពាក់ព័ន្ធនឹងការខ្ចីប្រាក់មានការកើនឡើង (ចំនួន ១០៨៣៧ សំណុំរឿងពាក់ព័ន្ធនឹងកិច្ចសន្យាខ្ចីបរិភោគស្មើនឹង ១៣% នៃសំណុំរឿងរដ្ឋប្បវេណីសរុប)។

២-សំណុំរឿងដែលប្ដឹងចូលមក គ២ ក៏មានចំនួនប្រមាណ ១៧% នៃបណ្ដឹងសុំអន្តរាគមន៍ពាក់ព័ន្ធនឹងសំណុំរឿងរដ្ឋប្បវេណីសរុប។

៣-តាមរយៈការសិក្សាលើសំណុំរឿងក្នុងក្របខណ្ឌ គ២ ក្រុមការងារពិនិត្យឃើញថា ការអនុវត្តច្បាប់ពាក់ព័ន្ធនឹងការកំណត់ការប្រាក់ និងការប្រាក់ឃើតយ៉ាវក្នុងកិច្ចសន្យាខ្ចីប្រាក់នៅមិនទាន់មានភាពច្បាស់លាស់ និង មិនទាន់មានសង្គតិភាពគ្នានៅឡើយ ។

៤-ចំពោះការសម្រេចក្នុងសំណុំរឿងពាក់ព័ន្ធនឹងការខ្ចីប្រាក់នេះ ចៅក្រមនៃសាលាដំបូងមួយចំនួនមិនបានយកចិត្តទុកដាក់លើការគណនាប្រាក់ដើមនៅសល់ ជាពិសេស ការគណនាការប្រាក់ដើមនៅសល់ ដោយកាត់ចេញនូវការប្រាក់ដែលបង់លើស និងការប្រាក់ឃើតយ៉ាវដែលបង់លើស។

៥-តាមការសម្រេចរបស់តុលាការមួយចំនួន កូនបំណុលត្រូវសងម្ចាស់បំណុលរហូតដល់ ៤៥% (ការប្រាក់ ១៨% + ការប្រាក់ឃើតយ៉ាវ ២៧%) ដោយមិនទាន់គិតប្រាក់សំណងខូចខាតផ្សេងទៀត។

# ការសម្រេចសេចក្តីរបស់តុលាការ

## សាលក្រមរដ្ឋប្បវេណីលេខ ០៧ "ជ" ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤ របស់សាលាដំបូងខេត្តតាកែវ

(ការបង្គាប់ឱ្យសងការប្រាក់ និងប្រាក់ពិន័យគិតពីថ្ងៃខកខានរហូតដល់ថ្ងៃសងគ្រប់ចំនួន)

**សេចក្តីសម្រេចបញ្ចប់**

១.បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ ភេទស្រី កើតថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៨៦, ឈ្មោះ ភេទប្រុស កើតថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៦៦, ឈ្មោះ ភេទប្រុស កើតថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៤, ឈ្មោះ ភេទប្រុស កើតថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៩ និងឈ្មោះ ភេទស្រី កើតថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០១ រួមគ្នាសងប្រាក់ដើមចំនួន ៣០.១០០ (បីម៉ឺនមួយរយដុល្លាអាមេរិក) ឱ្យទៅដើមចោទ **ធនាគារហត្ថា ម.ក** សាខាស្រុកត្រាំកក់ ។

២.បង្គាប់ឱ្យសហចុងចម្លើយបង់ការប្រាក់ចំនួន ១% (**មួយ**) ភាគរយ ក្នុងមួយខែ គិតលើប្រាក់ដើមនៅជំពាក់ចំនួន **៣០.១០០** (**បីម៉ឺនមួយរយដុល្លាអាមេរិក**) ដោយគិតចាប់ពីខែមិថុនា ឆ្នាំ២០២២ រហូតមកដល់ថ្ងៃសងគ្រប់ចំនួន ឱ្យទៅដើមចោទ ។

៣.បង្គាប់ឱ្យសហចុងចម្លើយបង់ប្រាក់ពិន័យលើការប្រាក់ដែលយឺតយ៉ាវចំនួន **២៧%** (**ម្ភៃប្រាំពីរ**) ភាគរយក្នុងមួយឆ្នាំ ដោយគិតចាប់ពីថ្ងៃខែមិថុនា ឆ្នាំ២០២២ រហូតមកដល់ថ្ងៃសងគ្រប់ចំនួន ឱ្យទៅដើមចោទ ។

-រយៈពេលកិច្ចសន្យា
(៦ ឧសភា ២០២១ -
៦ ឧសភា ២០២៨)
-ពេលខកខានបង់ប្រាក់
៦ មិថុនា ២០២២
-ពេលដាក់ពាក្យបណ្តឹង
(១៧ ឧសភា ២០២៣)

# សាលក្រមរដ្ឋប្បវេណីលេខ ១២២៣ ប ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ

(ការបង្គាប់ឱ្យសងការប្រាក់ និងប្រាក់ពិន័យគិតពីថ្ងៃខកខានរហូតដល់ថ្ងៃសងគ្រប់ចំនួន និងសំណងការខូចខាត ១៨%ក្នុងមួយឆ្នាំ)

-ថ្ងៃខកខានបង់ប្រាក់ (២៨ កញ្ញា ២០២២)

-ពេលដាក់ពាក្យបណ្ដឹង (២៦ ឧសភា ២០២២)

**សេចក្ដីសម្រេចបញ្ចប់**

១-ទទួលស្គាល់ពាក្យបណ្ដឹង ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២ ,ពាក្យសុំកែតម្រូវកម្មវត្ថុបណ្ដឹង ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២ និងពាក្យសុំផ្លាស់ប្ដូរ និងបន្ថែមកម្មវត្ថុបណ្ដឹង ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២ របស់លោកមេធាវី សុខ សុភ័ក្រ និងលោកមេធាវី ដោយទាមទាររបស់ដើមចោទ ដែលបង្គាប់ឱ្យ ក្រុមហ៊ុន ដែលមានដែលមានសមាជិកក្រុមហ៊ុនពាក់ព័ន្ធ៖ឈ្មោះ សងប្រាក់ទៅឱ្យ គ្រឹះស្ថានមីក្រូ ហិរញ្ញវត្ថុ សម្បត្តិហ្វាយនែន ភីអិលស៊ី ដែលមានតំណាងដោយលោក សឿង ស៊ីម៉ុន នូវ៖

ក-ប្រាក់ដើមចំនួន៨៥៨,៩៩០,២៩ (ប៉ែតសិបប្រាំ មុឺនប្រាំបីពាន់ប្រាំបួនរយកៅសិបដុល្លារ និងម្ភៃប្រាំបួនសេន)។

ខ-ការប្រាក់ស្មើនឹង១៨ %'ដប់ប្រាំបីភាគរយ" ក្នុង០១ឆ្នាំនៃប្រាក់ ដើមនៅសល់ជាក់ស្ដែង គិតពីថ្ងៃមិនអនុវត្តកាតព្វកិច្ច រហូតដល់ថ្ងៃសងគ្រប់ចំនួន។

គ-ការប្រាក់យឺតយ៉ាវស្មើនឹង២៧% (ម្ភៃប្រាំពីរភាគរយ) ក្នុង០១ឆ្នាំ នៃការប្រាក់សរុប គិតពីថ្ងៃយឺតយ៉ាវរហូតដល់ថ្ងៃ សងគ្រប់ចំនួន។

ឃ-សំណងនៃការខូចខាត ១៨%(ដប់ប្រាំបីភាគរយ) ក្នុង០១ឆ្នាំ នៃប្រាក់ដើមសល់ជាក់ស្ដែង គិតចាប់ពីថ្ងៃយឺតយ៉ាវ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

# សាលក្រមរដ្ឋប្បវេណីលេខ ៥៦៧"ម" ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤ របស់សាលាដំបូងរាជធានីភ្នំពេញ

## (ការបង្គាប់ឱ្យសងការប្រាក់រហូតដល់ថ្ងៃដាក់ពាក្យបណ្ដឹង និងការប្រាក់យឺតយ៉ាវរហូតដល់ពេលសងគ្រប់ និងសំណងការខូចខាត)

**សេចក្ដីសម្រេចបញ្ចប់**

១. បង្គាប់ឱ្យចុងចម្លើយឈ្មោះ ឈ្មោះ សងប្រាក់ដើម ចំនួន ២៧.៦៥៩ (ពីរម៉ឺនប្រាំពីរពាន់ប្រាំមួយរយហាសិបប្រាំបួន) ដុល្លារអាមេរិក ឱ្យទៅដើមចោទ។

១.១ បង់ការប្រាក់ចំនួន៨,២៥% ក្នុង១ឆ្នាំលើប្រាក់ដើមចំនួន ២៧.៦៥៩ (ពីរម៉ឺនប្រាំពីរពាន់ប្រាំមួយរយហាសិបប្រាំបួន) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣ រហូតដល់ថ្ងៃដាក់ពាក្យបណ្ដឹងថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ឱ្យទៅដើមចោទ។

១.២ បង់ការប្រាក់យឺតយ៉ាវចំនួន២៧% ក្នុង១ឆ្នាំលើប្រាក់ដើមចំនួន ២៧.៦៥៩ (ពីរម៉ឺនប្រាំពីរពាន់ប្រាំមួយរយហាសិបប្រាំបួន) ដុល្លារអាមេរិក ឱ្យទៅដើមចោទ គិតចាប់ពីថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ រហូតដល់ពេលសងចប់សព្វគ្រប់។

២. បង្គាប់ឱ្យចុងចម្លើយឈ្មោះ ឈ្មោះ សងប្រាក់ដើម ចំនួន ៤១.៥៩៩ (បួនម៉ឺនមួយពាន់ប្រាំរយកៅសិបប្រាំបួន) ដុល្លារអាមេរិក ឱ្យទៅដើមចោទ។

២.២ បង់ការប្រាក់ចំនួន ៨,២៥% ក្នុង១ឆ្នាំ លើប្រាក់ដើមចំនួន ៤១.៥៩៩ (បួនម៉ឺនមួយពាន់ប្រាំរយកៅសិបប្រាំបួន) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣ រហូតដល់ថ្ងៃដាក់ពាក្យបណ្ដឹងថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ឱ្យទៅដើមចោទ។

២.៣ បង់ការប្រាក់យឺតយ៉ាវចំនួន ២៧% ក្នុង១ឆ្នាំ លើប្រាក់ដើមចំនួន ៤១.៥៩៩ (បួនម៉ឺនមួយពាន់ប្រាំរយកៅសិបប្រាំបួន) ដុល្លារអាមេរិក ឱ្យទៅដើមចោទ គិតចាប់ពីថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ រហូតដល់ពេលសងចប់សព្វគ្រប់។

៤. បង្គាប់ឱ្យចុងចម្លើយសងសំណងការខូចខាតចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល ឱ្យទៅដើមចោទ។

-រយៈពេលកិច្ចសន្យា (២៥ សីហា ២០២២-២៥ សីហា ២០៤៧)
-ថ្ងៃខកខានបង់ប្រាក់ (២០ មេសា ២០២៣)
-ពេលដាក់ពាក្យបណ្ដឹង (៦ កញ្ញា ២០២៣)

# សាលក្រមរដ្ឋប្បវេណីលេខ ២១២៣ "គ" ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៤ របស់សាលាដំបូងរាជធានីភ្នំពេញ

## (ការបង្គាប់ឱ្យសងការប្រាក់ និងការប្រាក់យឺតយ៉ាវគិតចាប់ពីពេលកំណត់ត្រូវសងរហូតដល់សងគ្រប់ចំនួន)

### សេចក្ដីសម្រេចបញ្ចប់

១-ទទួលពាក្យបណ្ដឹងចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤ របស់ដើមចោទ និង បណ្ដឹងតបថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤ ដើមបណ្ដឹងតប និងជាសហចុងចម្លើយ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់។

២-ច្រានចោល ពាក្យបណ្ដឹងតបចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤ របស់ ដើមបណ្ដឹងតប និងជាសហចុងចម្លើយ ឈ្មោះ ឈ្មោះ ឈ្មោះ និងឈ្មោះ គ្រប់ចំណុចទាំងអស់។

៣-បង្គាប់ឱ្យ សហចុងចម្លើយ និងជាសហដើមបណ្ដឹងតប ឈ្មោះ ឈ្មោះ ឈ្មោះ និង ឈ្មោះ រួមគ្នាសងដោយកាតព្វកិច្ចសាមគ្គី ទៅឱ្យដើមចោទ ធនាគារវីង (ខេមបូឌា) ម.ក នូវទឹកប្រាក់នៅជំពាក់ដូចខាងក្រោម៖

៣.១-ប្រាក់ជំពាក់សម្រាប់គណនីទី១ តាមកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១

ក-ប្រាក់ដើមនៅជំពាក់ចំនួន $៣៤៩.៤៨១,១៨ (សាមសិបបួនម៉ឺន ប្រាំបួនពាន់ បួនរយ ប៉ែតសិបមួយ និងដប់ប្រាំបីសេន) ដុល្លាអាមេរិក។

ខ-ការប្រាក់ក្នុងអត្រា៩%(ប្រាំបួន)ភាគរយក្នុងមួយឆ្នាំ លើប្រាក់ដើមនៅជំពាក់ចំនួន $៣៤៩.៤៨១,១៨ (សាមសិបបួនម៉ឺន ប្រាំបួនពាន់ បួនរយ ប៉ែតសិបមួយ និងដប់ប្រាំបីសេន) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៣ រហូតដល់ថ្ងៃដាក់ពាក្យបណ្ដឹង។

គ-ប្រាក់ពិន័យលើការយឺតយ៉ាវចំនួន ២៧%(ម្ភៃប្រាំពីរភាគរយ)ក្នុងមួយឆ្នាំ នៃចំនួនទឹកប្រាក់ដែលត្រូវទូទាត់សង គិតចាប់ពីពេលដល់កំណត់ត្រូវសង រហូតដល់ពេលទទួលបានការសងគ្រប់ចំនួន។

៣.២-ប្រាក់ជំពាក់សម្រាប់គណនីទី២ តាមកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២

ក-ប្រាក់ដើមនៅជំពាក់ចំនួន $៦០.៤០៣,៣៦ (ប្រាំមួយម៉ឺន បួនរយបី និងសាមសិបប្រាំមួយសេន)ដុល្លាអាមេរិក។

ខ-ការប្រាក់ក្នុងអត្រា ៩,៥០% (ប្រាំបួនក្បៀសហាសិប)ភាគរយក្នុងមួយឆ្នាំ លើប្រាក់ដើមនៅជំពាក់ ចំនួន $៦០.៤០៣,៣៦(ប្រាំមួយម៉ឺន បួនរយបី និងសាមសិបប្រាំមួយសេន)ដុល្លាអាមេរិក គិតចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២៣ រហូតដល់ថ្ងៃដាក់ពាក្យបណ្ដឹង។

គ-ប្រាក់ពិន័យលើការយឺតយ៉ាវចំនួន ២៧%(ម្ភៃប្រាំពីរភាគរយ)ក្នុងមួយឆ្នាំ នៃចំនួនទឹកប្រាក់ដែលត្រូវទូទាត់សង គិតចាប់ពីពេលដល់កំណត់ត្រូវសង រហូតដល់ពេលទទួលបានការសងគ្រប់ចំនួន។

៤-ច្រានចោល ការទាមទាររបស់ដើមចោទ លើការប្រាក់ពិន័យករណីបំពានលក្ខខណ្ឌ ១៨% (ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំ $៦០.៤០៣,៣៦ (ប្រាំមួយម៉ឺន បួនរយបី និងសាមសិបប្រាំមួយសេន)ដុល្លាអាមេរិក គិតចាប់ពីថ្ងៃទី២ ខែមករា ឆ្នាំ២០២៤ រហូតដល់ថ្ងៃបានសងគ្រប់ចំនួន។

៥-ច្រានចោល ការទាមទាររបស់ដើមចោទ លើប្រាក់សំណងនៃការខូចខាតជំងឺចិត្ត ការខាតបង់ពេលវេលា ការចំណាយផ្សេងៗ និងសេវាកម្មច្បាប់ ដែលបណ្ដាលមកពីការមិនអនុវត្តកាតព្វកិច្ចចំនួន ២០.០០០ (ម្ភៃពាន់)ដុល្លារអា មេរិក។

៦-អនុវត្តបណ្ដោះអាសន្ន ត្រង់ចំណុច ៣.១.ក (ប្រាក់ដើមនៅជំពាក់ចំនួន $៣៤៩.៤៨១,១៨ (សាមសិបបួនម៉ឺន ប្រាំបួនពាន់ បួនរយ ប៉ែតសិបមួយ និងដប់ប្រាំបីសេន) ដុល្លាអាមេរិក) និង ត្រង់ចំណុច ៣.២.ក (ប្រាក់ដើមនៅជំពាក់ចំនួន $ ៦០.៤០៣,៣៦ (ប្រាំមួយម៉ឺន បួនរយបី និងសាមសិបប្រាំមួយសេន)ដុល្លារអាមេរិក)។

៧-ប្រាប់ប្រដាប់ក្ដី ជាបន្ទុករបស់សហចុងចម្លើយ។

៨-សាលក្រមនេះ បញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៤ ចំពោះមុខដើមចោទ និងសហចុងចម្លើយ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៤ បើកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា

# សាលក្រមរដ្ឋប្បវេណីលេខ ២១២៣ "គ" ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០២៤ របស់សាលាដំបូងរាជធានីភ្នំពេញ

## (ការបង្គាប់ឱ្យសងការប្រាក់រហូតដល់ថ្ងៃដាក់ពាក្យបណ្ដឹង និងការប្រាក់យឺតយ៉ាវរហូតដល់ពេលសងគ្រប់)

**សេចក្ដីសម្រេចបញ្ចប់**

៣-បង្គាប់ឱ្យ សហចុងចម្លើយ និងជាសហដើមបណ្ដឹងតប ឈ្មោះ ឈ្មោះ ឈ្មោះ និង ឈ្មោះ រួមគ្នាសងដោយកាតព្វកិច្ចសាមគ្គី ទៅឱ្យដើមចោទ ធនាគារវីង (ខេមបូឌា) ម.ក នូវទឹកប្រាក់នៅជំពាក់ដូចខាងក្រោម៖

៣.១-ប្រាក់ជំពាក់សម្រាប់គណនីទី១ តាមកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១

ក-ប្រាក់ដើមនៅជំពាក់ចំនួន $៣៤៩.៤៨១,១៨ (សាមសិបបួនម៉ឺន ប្រាំបួនពាន់ បួនរយ ប៉ែតសិបមួយ និងដប់ប្រាំបីសេន) ដុល្លារអាមេរិក។

ខ-ការប្រាក់ក្នុងអត្រា៩%(ប្រាំបួន)ភាគរយក្នុងមួយឆ្នាំ លើប្រាក់ដើមនៅជំពាក់ចំនួន $៣៤៩.៤៨១,១៨ (សាមសិបបួនម៉ឺន ប្រាំបួនពាន់ បួនរយ ប៉ែតសិបមួយ និងដប់ប្រាំបីសេន) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៣ រហូតដល់ថ្ងៃដាក់ពាក្យបណ្ដឹង។

គ-ប្រាក់ពិន័យលើការយឺតយ៉ាវចំនួន ២៧%(ម្ភៃប្រាំពីរភាគរយ)ក្នុងមួយឆ្នាំ នៃចំនួនទឹកប្រាក់ដែលត្រូវខូចទាត់សង គិតចាប់ពីពេលដល់កំណត់ត្រូវសង រហូតដល់ពេលទទួលបានការសងគ្រប់ចំនួន។

៣.២-ប្រាក់ជំពាក់សម្រាប់គណនីទី២ តាមកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២

ក-ប្រាក់ដើមនៅជំពាក់ចំនួន $៦០.៤០៣,៣៦ (ប្រាំមួយម៉ឺន បួនរយបី និងសាមសិបប្រាំមួយសេន)ដុល្លារអាមេរិក។

ខ-ការប្រាក់ក្នុងអត្រា ៩,៥០% (ប្រាំបួនក្បៀសហាសិប)ភាគរយក្នុងមួយឆ្នាំ លើប្រាក់ដើមនៅជំពាក់ ចំនួន $៦០.៤០៣,៣៦(ប្រាំមួយម៉ឺន បួនរយបី និងសាមសិបប្រាំមួយសេន)ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២៣ រហូតដល់ថ្ងៃដាក់ពាក្យបណ្ដឹង។

គ-ប្រាក់ពិន័យលើការយឺតយ៉ាវចំនួន ២៧%(ម្ភៃប្រាំពីរភាគរយ)ក្នុងមួយឆ្នាំ នៃចំនួនទឹកប្រាក់ដែលត្រូវខូចទាត់សង គិតចាប់ពីពេលដល់កំណត់ត្រូវសង រហូតដល់ពេលទទួលបានការសងគ្រប់ចំនួន។

-រយៈពេលកិច្ចសន្យា

កិច្ចសន្យាទី១៖

(១៧ វិច្ឆិកា ២០២១ - ១ វិច្ឆិកា ២០២៣)

កិច្ចសន្យាទី២៖

(១៨ កក្កដា ២០២២ - ១ តុលា ២០២៣)

-ពេលដាក់ពាក្យបណ្ដឹង

(២៦ មករា ២០២៤)

# សាលដីកាលេខ០៨ "ង" ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤ របស់សាលាឧទ្ធរណ៍បាត់ដំបង ដែលសម្រេចតម្កល់សាលក្រមលេខ ២៦៦ "ធ" ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ របស់សាលាដំបូងបាត់ដំបង

-បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ២៦៦ "ឆ" ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តបាត់ដំបង ដែលបានសម្រេចៈ

១-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ          និងប្រពន្ធឈ្មោះ          សងប្រាក់ចំនួន ៧៦,១៣០.៨៧ ដុល្លារអាមេរិក (ប្រាំពីរម៉ឺនប្រាំមួយពាន់មួយរយសាមសិបដុល្លារអាមេរិក និងប៉ែតសិបប្រាំពីរសេន) ឱ្យទៅដើមចោទធនាគារស្ថាបនាភីអិលស៊ី សាខាខេត្តបាត់ដំបង។

២-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ          និងប្រពន្ធឈ្មោះ          សងការប្រាក់ទៅដើមចោទធនាគារស្ថាបនាភីអិលស៊ី សាខាខេត្តបាត់ដំបង ចំនួន០.៩៥% (សូន្យកណ្តក់សញ្ញាកៅសិបប្រាំភាគរយ) ក្នុងមួយខែ ឬស្មើនឹង ១១.៤០(ដប់មួយកណ្តក់សញ្ញាសែសិបភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ចំនួន ៧៦,១៣០.៨៧ ដុល្លារអាមេរិក (ប្រាំពីរម៉ឺនប្រាំមួយពាន់មួយរយសាមសិបដុល្លារអាមេរិក និងប៉ែតសិបប្រាំពីរសេន) គិតចាប់ពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៦។

៣-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ          និងប្រពន្ធឈ្មោះ          សងការប្រាក់ពិន័យទៅដើមចោទធនាគារស្ថាបនាភីអិលស៊ី សាខាខេត្តបាត់ដំបង ក្នុងអត្រាការប្រាក់ពិន័យចំនួន២%(ពីរភាគរយ) ក្នុងមួយខែ ឬ ២៤%(ម្ភៃបួនភាគរយ) ក្នុងមួយឆ្នាំលើប្រាក់ចំនួន៧៦,១៣០.៨៧ ដុល្លារអាមេរិក (ប្រាំពីរម៉ឺនប្រាំមួយពាន់មួយរយសាមសិបដុល្លារអាមេរិកនិងប៉ែតសិបប្រាំពីរសេន) គិតចាប់ពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២ រហូតដល់ថ្ងៃដែលបានទូទាត់បំណុលចប់សព្វគ្រប់។

-រយៈពេលកិច្ចសន្យា
(២៧ ឧសភា ២០២០
-១២ តុលា ២០២៦)
-ថ្ងៃខកខានបង់ប្រាក់
១៤ មីនា ២០២២
-សាលក្រមចុះថ្ងៃទី
១៤ កញ្ញា ២០២៣
-បង្គាប់ឱ្យសងការប្រាក់
រហូតដល់
២៩ តុលា ២០២៦
(រយៈពេលនៃកិច្ចសន្យាទាំងមូល)

# សាលក្រមរដ្ឋប្បវេណីលេខ ១០៩០ "ខ១" ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ

(ការបង្គាប់ឱ្យសងការប្រាក់ត្រឹមកាលបរិច្ឆេទបញ្ចប់កិច្ចសន្យា
និងការប្រាក់យឺតយ៉ាវរហូតដល់ពេលសងគ្រប់ចំនួន និងសំណងការខូចខាត)

## IV-សេចក្តីសម្រេចបញ្ចប់

១-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ ឈ្មោះ ឈ្មោះ និង ឈ្មោះ រួមគ្នាសងទៅដើមចោទ ធនាគារ ប៊ូយ៉ុងខ្មែរ នូវ៖

១.១-ប្រាក់ចំនួន ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក ។

១.២-ការប្រាក់ ៨.៥០% ក្នុងមួយឆ្នាំ លើប្រាក់ចំនួន ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ ។

១.៣-ការប្រាក់យឺតយ៉ាវចំនួន ២៤% ក្នុងមួយឆ្នាំ លើប្រាក់ចំនួន ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ រហូតដល់ពេលសងរួចគ្រប់ចំនួន ។

១.៤-ប្រាក់សំណងជំងឺចិត្តចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល ។

២-សាលក្រមនេះមានអានុភាពអនុវត្តជាបណ្តោះអាសន្នលើចំណុចទី១.១ នៃសេចក្តីសម្រេចបញ្ចប់ខាងលើនេះ ។

៣-ច្រានចោលការទាមទារផ្សេងពីនេះ ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

-កិច្ចសន្យាខ្ចីប្រាក់
(២៥ ឧសភា ២០១៩-
២៦ មេសា ២០២១)
-ថ្ងៃខកខានបង់ប្រាក់
(២៦ កុម្ភៈ ២០២០)
-ពេលដាក់ពាក្យបណ្តឹង
(១៧ មីនា ២០២៣)

## សាលក្រមរដ្ឋប្បវេណីលេខ ០៨ "ង"/១១១ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តសៀមរាប

### (ការបង្គាប់ឱ្យសងការប្រាក់ពីថ្ងៃខកខាតរហូតដល់ថ្ងៃដាក់ពាក្យបណ្តឹង និងការប្រាក់យឺតយ៉ាវចាប់ពីថ្ងៃដាក់ពាក្យបណ្តឹង និងសំណងការខូចខាត)

**សេចក្តីសម្រេចបញ្ចប់**

១- ឱ្យសហចុងចម្លើយឈ្មោះ ឈ្មោះ និងឈ្មោះ រួមគ្នាសងប្រាក់ទៅឱ្យដើមចោទ **ធនាគារ តៃវ៉ាន់ ខូអបភើរេធីវ សាខាភ្នំពេញ "សាខារងសៀមរាប"** មានអ្នកតំណាងស្របច្បាប់លោក នឹងលោក មេធាវីតំណាងដោយអាណត្តិ នូវទឹកប្រាក់ដូចខាងក្រោម៖

១.១- ប្រាក់ដើមចំនួន USD ២៧១,៧០០ (ម្ភៃប្រាំពីរម៉ឺនមួយពាន់ប្រាំពីររយ) ដុល្លារអាមេរិក ។

១.២- ការប្រាក់ដែលបានបង្គរចំនួន USD ៣៣,០៥១.៩៨ (បីម៉ឺនបីពាន់ហាសិបមួយចុចកៅសិបប្រាំបី)ដុល្លារអាមេរិក ចាប់ពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ ។

១.៣- ការប្រាក់ចំនួន ៧% ក្នុងមួយឆ្នាំ គិតចាប់ពីថ្ងៃខកខានមិនបានបង់ គឺថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ រហូតដល់ថ្ងៃដាក់ពាក្យបណ្តឹងនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣ ។

១.៤- អត្រាការប្រាក់យឺតយ៉ាវមិនអនុវត្តកាតព្វកិច្ច ១.៥(មួយចុចប្រាំដងនៃអត្រាការប្រាក់បច្ចុប្បន្ន៧%) ស្មើនឹងអត្រាការប្រាក់ ៧% x ១.៥ ដង = ១០.៥% ក្នុងមួយឆ្នាំ ទៅលើប្រាក់ដើម គិតចាប់ពីថ្ងៃដាក់ពាក្យបណ្តឹងនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣ រហូតដល់ថ្ងៃសងចប់ ។

២- បង្គាប់ឱ្យសហចុងចម្លើយ រួមគ្នាសងការខូចខាត និងសេវាកម្មផ្សេងៗ ជាប្រាក់ចំនួន ៥.០០០.០០០(ប្រាំលាន)រៀល ឱ្យទៅដើមចោទ នៅពេលសាលក្រមចូលជាស្ថាពរ ។ ការទាមទារលើសពីនេះត្រូវច្រានចោល ។

-កិច្ចសន្យាខ្ចីប្រាក់ (២០ មេសា ២០២០)
-ថ្ងៃខកខានបង់ប្រាក់ (២៩ មិថុនា ២០២២)
-ពេលដាក់ពាក្យបណ្តឹង (១៤ កុម្ភៈ ២០២៣)

# ២-ចំណោទបញ្ហាគតិយុត្ត

១- តើពាក្យថា "ការប្រាក់ឃើតយ៉ាវ" ដែលត្រូវបានប្រើក្នុងសេចក្តីសម្រេចតុលាការគឺជាអ្វី? គឺជាការប្រាក់ ឬ ជាការកំណត់ជាមុននូវសំណងនៃការខូចខាត?

២- តើការប្រាក់ និង ការប្រាក់ឃើតយ៉ាវ ត្រូវកំណត់បែបណានៅពេលដែលម្ចាស់បំណុលប្តឹងទៅតុលាការទាមទារឱ្យកូនបំណុលសងប្រាក់កម្ចីមកវិញ (មូលដ្ឋាននៃការគណនា និងរយៈពេល)?

៣-តើការសម្រេចបង្គាប់ឱ្យកូនបំណុលសងទាំង ការប្រាក់ និងការប្រាក់ឃើតយ៉ាវ ចាប់ពីថ្ងៃខកខានក្នុងការសងប្រាក់រហូតដល់ពេលសងប្រាក់ដើមរួចទាំងអស់ គឺជាការសម្រេចត្រឹមត្រូវដែរឬទេ?

៤-តើប្រាក់ដើមនៅសល់ដែលត្រូវសងទៅម្ចាស់បំណុល ត្រូវគណនាបែបណា?

៥-តើតុលាការគួរពិនិត្យដោយធន្ទានុសិទ្ធិក្នុងការយកភាគនៃការប្រាក់ និងភាគនៃការប្រាក់ឃើតយ៉ាវដែលបង់លើសច្បាប់កំណត់ ទៅកាត់កងជាមួយនឹងប្រាក់ដើមនៅសល់ មុននឹងសម្រេចអំពីប្រាក់ដើមនៅសល់ដែរឬទេ?

# ៣-ក្របខណ្ឌច្បាប់

❖ក្រឹត្យច្បាប់លេខ៣៨ (១៩៨៨) មានចាប់ពីមាត្រា៥៦ ដល់មាត្រា៦៣

មាត្រា៥៩ "នឹងមិនអាចយកការប្រាក់ខ្ចីបាន លុះត្រាតែមានការព្រមព្រៀងនៃគូភាគីក្នុងកិច្ចសន្យា។ អត្រានៃការប្រាក់មិនត្រូវឱ្យលើសពី ៥ ភាគរយក្នុងមួយឆ្នាំ លើកលែងតែមានបទបញ្ញត្តិចែងផ្ទុយពីនេះ។ (ត្រូវបាននិរាករណ៍)

❖ក្រមរដ្ឋប្បវេណី (២០០៧) មានចាប់ពីមាត្រា៥៨៣ ដល់មាត្រា៥៨៦

មាត្រា៥៨៤ កថាខណ្ឌទី២ "ក្នុងករណីដែលត្រូវបង់ការប្រាក់តាមការព្រមព្រៀងរវាងភាគី ឬបញ្ញត្តិច្បាប់ ប្រសិនបើភាគីពុំបានកំណត់អំពីអត្រាការប្រាក់ទេនោះ ត្រូវអនុលោមតាមអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ដែលបញ្ញត្តិក្នុងក្រមនេះ ឬ ច្បាប់ពិសេស។

មាត្រា៥៨៥ កថាខណ្ឌទី១ "អត្រាការប្រាក់ដែលត្រូវកម្រិត សំដៅទៅលើ អត្រាការប្រាក់អតិបរមាដែលអាចកំណត់បានដោយស្របច្បាប់ តាមការព្រមព្រៀងរបស់ភាគី"។

# ៣-ក្របខណ្ឌច្បាប់ (ត)

❖ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី (២០១១)៖ មាត្រា១៧

❖ ប្រកាសស្តីពី អត្រាការប្រាក់ដែលត្រូវបានកម្រិត (២១/១២/២០១១)

❖ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា

មាត្រា៧ ចំណុចទី១២ ធនាគារកណ្តាលមានមុខងារ និងភារកិច្ច... "កំណត់អត្រាការប្រាក់"។

❖ ប្រកាសស្តីពីការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់ (០៩/០៩/២០០៩)

ប្រការ១ "គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានសិទ្ធិក្នុងការកំណត់នូវអត្រាការប្រាក់... លើការផ្តល់ឥណទានជាប្រាក់រៀលនិងជារូបិយប័ណ្ណ យោងតាមលទ្ធភាព និងគោលនយោបាយអត្រាការប្រាក់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និមួយៗ"។

❖ ប្រកាសស្តីពីការកំណត់ពិដានអត្រាការប្រាក់ឥណទាន (១៣/០៣/២០១៧)

ប្រការ១ និងប្រការ៤ "...គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលធ្វើប្រតិបត្តិការឥណទានជនបទ...ត្រូវកំណត់ អត្រាការប្រាក់ឥណទានមិនលើសពី ១៨% ក្នុងមួយឆ្នាំសម្រាប់គ្រប់ឥណប្រតិទាននៃឥណទាន"។

# ៣-ក្របខណ្ឌច្បាប់ (ត)

❖ក្រមរដ្ឋប្បវេណី និងច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី បានកំណត់អំពីរបបគតិយុត្តពាក់ព័ន្ធនឹងការប្រាក់ និងការប្រាក់ឃើតឃ៉ាវ នៅក្នុងកិច្ចសន្យាខ្ចីប្រាក់។

❖បទប្បញ្ញត្តិដែលកំណត់ដោយធនាគារជាតិពាក់ព័ន្ធតែការកំណត់ពិដានការប្រាក់ប៉ុណ្ណោះ។ ប៉ុន្តែ បទប្បញ្ញត្តិនេះមិនពាក់ព័ន្ធនឹងការប្រាក់ឃើតឃ៉ាវ និងមិនបានកំណត់វិធានពិសេសណាមួយសម្រាប់អនុវត្តចំពោះកិច្ចសន្យាឥណទានដែលផ្ដល់ដោយធនាគារឯកជននោះទេ។

❖ហេតុនេះ បទបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តចំពោះការប្រាក់ឃើតឃ៉ាវ។

# ក-ការប្រាក់

- មាត្រា ៥៨៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី៖ "ការប្រាក់ សំដៅទៅលើចំនួនទឹកប្រាក់ដែលត្រូវបានផ្តល់ទៅឱ្យ តាមសមាមាត្រនៃអំឡុងពេលនៃការប្រើប្រាស់" ។

- មាត្រា ៥៨៤ នៃក្រមរដ្ឋប្បវេណី៖

  ១-អត្រាការប្រាក់ អាចកំណត់តាមច្បាប់ ឬតាមការព្រមព្រៀង

  ២-ក្នុងករណីដែលត្រូវបង់ការប្រាក់ បើភាគីពុំបានកំណត់អត្រាការប្រាក់នោះទេ អត្រាការប្រាក់នេះត្រូវកំណត់ស្របតាមក្រមនេះ។

  ៣-អត្រាការប្រាក់តាមការព្រមព្រៀង ដែលហួសអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ត្រូវមានធ្វើជាលាយលក្ខណ៍អក្សរ។

- មាត្រា៥៩១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី៖ អ្នកខ្ចីនៃកិច្ចសន្យាខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ ត្រូវបង់ការប្រាក់តាមបញ្ញត្តិពីមាត្រា៥៨៤ ដល់មាត្រា៥៨៦ នៃក្រមនេះ។

- មាត្រា ៣១៨ នៃក្រម (អត្រាការប្រាក់ដែលកំណត់ដោយច្បាប់)៖ "ចំពោះកាតព្វកិច្ចដែលត្រូវបង្កើតការប្រាក់ ក្នុងករណីដែលគ្មានកំណត់ផ្សេងទេ ត្រូវគិតអត្រាការប្រាក់ចំនួន ៥ % ក្នុងមួយឆ្នាំ"។

# ការប្រាក់ (បន្ត)

❖ មាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី (ការកម្រិតអត្រាការប្រាក់)

១-អត្រាការប្រាក់ដែលត្រូវបានកម្រិត ជាអត្រាការប្រាក់អតិបរមាដែលអាចកំណត់បាន

២-ភាគីមិនអាចកំណត់អត្រាការប្រាក់លើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិត

៣-ភាគនៃអត្រាការប្រាក់ដែលលើសពីកម្រិតអតិបរមា ត្រូវទុកជាមោឃៈ

៤-ភាគនៃការប្រាក់ដែលបង់លើស ត្រូវចាត់ទុកថាជាការកាត់បំណុលទៅលើប្រាក់ដើម។

*៥-ចំពោះការអនុវត្តមាត្រានេះ នៅក្នុងករណីដែលចំនួនប្រាក់ដើមលើកិច្ចសន្យាខុសពីចំនួនទឹកប្រាក់នៃវត្ថុដែលអ្នកឱ្យខ្ចីបានប្រគល់ឱ្យជាក់ស្តែង ដូចជាករណីនៃការប្រគល់ប្រាក់ដើមដោយដកការប្រាក់ដែលត្រូវបង់នាពេលអនាគត ជាអាទិ៍ ចំនួនទឹកប្រាក់នៃវត្ថុដែលអ្នកឱ្យខ្ចីបានប្រគល់ដោយជាក់ស្តែងទៅឱ្យអ្នកខ្ចីនោះ ត្រូវទុកជាចំនួនប្រាក់ដើម។*

*៦-ចំពោះការអនុវត្តមាត្រានេះ ប្រាក់ និងវត្ថុផ្សេងទៀត ដែលអ្នកឱ្យខ្ចីបានទទួលក្រៅពីប្រាក់ដើម ទាក់ទងទៅនឹងកិច្ចសន្យាខ្ចីបរិភោគ ទោះបីជាបានទទួលនៅក្នុងនាមជាប្រាក់រង្វាន់ កម្រៃជើងសារ កម្រៃសើុបអង្កេត និងកម្រៃផ្សេងៗទៀតក៏ដោយ ត្រូវចាត់ទុកថាជាការប្រាក់។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសោហ៊ុយនៃការធ្វើកិច្ចសន្យា និងសោហ៊ុយនៃការសង។*

# ការប្រាក់ (បន្ត)

- អំឡុងពេលដែលកើតមាននូវការប្រាក់ គឺជាអំឡុងពេលនៃការប្រើប្រាស់ដើម គិតចាប់ពីថ្ងៃទទួលប្រាក់ រហូតដល់ថ្ងៃត្រូវសងប្រាក់ដើម ហើយក្រោយពេលកំណត់សងបានកន្លងផុត គឺមិនអាចទាមទារការប្រាក់បានទេ។
- អ្វីដែលកើតឡើងក្រោយពេលកំណត់សងបានមកដល់ គឺជាប្រាក់សំណងការខូចខាតដោយការយឺតយ៉ាវ ដែលជាកម្មវត្ថុនៃបណ្តឹងដោយឡែកពីសិទ្ធិលើបំណុលដែលជាការប្រាក់។

# ខ-ការប្រាក់យឺតយ៉ាវ

❖ មាត្រា ៣៩៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ៖ "ក្នុងករណីដែលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចទេ ម្ចាស់បំណុលអាចទាមទារ សំណងនៃការខូចខាត ដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ចនោះបាន"។

❖ មាត្រា ៤០៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី៖ "ម្ចាស់បំណុល និង កូនបំណុល អាចកំណត់ជាមុននូវការសន្យាពិសេសអំពីលក្ខខណ្ឌ និង ចំនួនសំណងការខូចខាត"។

❖ មាត្រា១៧ នៃ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី៖

២-ចំពោះការព្រមព្រៀងអំពី ការកំណត់ជាមុននូវចំនួននៃសំណង ក្នុងករណីមិនអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យាខ្ចីបរិភោគ...។

៣-ប្រកាសខាងលើអាចកំណត់អត្រាដែលកំណត់ក្នុងកថាខណ្ឌទី២ ខាងលើបាន ត្រឹមទំហំពី ១,២ ទៅ ២ ដង នៃអត្រាការប្រាក់ដែលត្រូវបានកម្រិត...។

❖ ប្រការ ២ នៃប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត៖ "អត្រាការប្រាក់ដែលព្រមព្រៀងជាមុនក្នុងការសងសំណងក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់"។ (មិនប្រើពាក្យ **ការប្រាក់យឺតយ៉ាវ** )

# ការប្រាក់យឺតយ៉ាវ (បន្ត)

❖ ពាក្យ ប្រាក់ពិន័យ មិនមានក្នុងច្បាប់នោះទេ។ ប្រាក់ពិន័យនេះ គឺជាសំណងនៅពេលមិនអនុវត្តកាតព្វកិច្ច។ យើងអាចបកស្រាយថា ប្រាក់ពិន័យគឺសំដៅលើប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា ហើយប្រាក់ធានាសំណងនេះត្រូវសន្មតថា ជាការកំណត់ជាមុននូវចំនួននៃសំណង ( *មាត្រា៤០៣ កថាខណ្ឌទី៥ នៃក្រមរដ្ឋប្បវេណី៖ ប្រាក់ធានាសំណងក្នុងករណីបំពានសន្យា ត្រូវសន្មតថាជាការកំណត់ជាមុននូវចំនួននៃសំណង*)

❖ គួរឈប់ប្រើពាក្យ ការប្រាក់យឺតយ៉ាវ ដោយប្តូរមកជា "សំណងនៃការខូចខាត"

❖ គួរប្រើពាក្យថា "សំណងនៃការខូចខាត ក្នុងអាត្រា.....ភាគរយក្នុងមួយឆ្នាំ នៃប្រាក់.....គិតចាប់ពី....រហូតដល់ថ្ងៃ.........."

❖ សំណងនៃការខូចខាត មាន ២ ករណី៖

១-ការប្រាក់យឺតយ៉ាវ (សំណងនៃការខូចខាត) ចំពោះប្រាក់ (ចំណែកនៃប្រាក់ដើមប្រចាំខែ) ដែលមិនបានបង់មុនពេលកំណត់សងមកដល់ ឬមុនពេលបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល)។ ការប្រាក់ដែលខកខានប្រចាំខែមិនអាចយកមកជាមូលដ្ឋាននៃការគណនាការប្រាក់យឺតយ៉ាវ (សំណងនៃការខូចខាត) ទៀតបានឡើយ (មាត្រា៥៨៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)

២-ការប្រាក់យឺតយ៉ាវ (សំណងនៃការខូចខាត) ចាប់ពីពេលដល់ពេលកំណត់សងមកដល់ ឬដល់ពេលបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល រហូតដល់ពេលសងប្រាក់ដើមដែលនៅសល់រួចរាល់

## (១)-តើការប្រាក់ត្រូវកំណត់បែបណានៅពេលដែលម្ចាស់បំណុលប្តឹងទៅតុលាការទាមទារឱ្យកូនបំណុលសងប្រាក់វិញ?

❖ មាត្រា៥៨៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី៖ "ការប្រាក់ សំដៅទៅលើចំនួនទឹកប្រាក់ដែលត្រូវបានផ្តល់ទៅឱ្យ តាមសមាមាត្រនៃអំឡុងពេលនៃការប្រើប្រាស់ ក្នុងនាមជាតម្លៃតបចំពោះការប្រើប្រាស់ប្រាក់ដែលត្រូវបានប្រគល់ឱ្យអ្នកខ្ចី ហើយដែលត្រូវគណនាដោយយកចំនួនទឹកប្រាក់ មកគុណជាមួយនឹងអត្រាដែលត្រូវបានកំណត់"។

❖ មាត្រា ៣៣០ នៃក្រមរដ្ឋប្បវេណី (ប្រយោជន៍នៃការកំណត់ពេល)

១-ការកំណត់ពេល ត្រូវសន្មតថា បានជាប្រយោជន៍របស់កូនបំណុល។

២-ប្រយោជន៍នៃការកំណត់ពេលនេះអាចបោះបង់ចោលបាន លុះត្រាតែមិននាំឱ្យមានការខូចខាតដោយមិនត្រឹមត្រូវ ដល់ភាគីម្ខាងទៀត។

❖ មាត្រា ៣២៩ កថាខណ្ឌទី២ នៃក្រម៖ "ក្នុងករណីដែលមានកំណត់ពេលចប់ចំពោះអានុភាពនៃកិច្ចសន្យា អានុភាពនោះត្រូវរលត់នៅពេលកំណត់នោះមកដល់"។

## (១)-តើការប្រាក់ត្រូវកំណត់បែបណានៅពេលដែលម្ចាស់បំណុលប្ដឹងទៅតុលាការទាមទារឱ្យកូនបំណុលសងប្រាក់វិញ?

❖ដារួម៖

១-ការប្រាក់អាចកំណត់បានត្រឹមពេលកំណត់សងមកដល់ (ត្រឹមតែកាលកំណត់ក្នុងកិច្ចសន្យា ឬ ថ្ងៃនៃការបាត់បង់ផលប្រយោជន៍នៃកំណត់ពេល)។

២-មិនអាចមានការប្រាក់ទៀតទេ គិតចាប់ពីពេលដែលកាលកំណត់សងបានមកដល់ តាមកាលបរិច្ឆេទកំណត់ក្នុងកិច្ចសន្យា ឬ ដោយការបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល (ពាក្យបណ្ដឹងទៅតុលាការតែងធ្វើក្រោយពេលកំណត់សងមកដល់)។

៣-បើកិច្ចសន្យាមិនបានកំណត់ពេលសងទេ ការប្រាក់ត្រូវគិតត្រឹមពេលដែលម្ចាស់បំណុលទាមទារឱ្យកូនបំណុលសង (មាត្រា៥៩៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី) តាមរយៈការដាស់តឿន ដោយកំណត់ពេលសមរម្យ (ថ្ងៃផុតកំណត់ដែលមានក្នុងការដាស់តឿន)។

# (២)-តើការប្រាក់យឺតយ៉ាវ (សំណងនៃការខូចខាត) ត្រូវកំណត់បែបណានៅពេលដែលម្ចាស់បំណុលប្តឹងទៅតុលាការទាមទារឱ្យកូនបំណុលសងប្រាក់វិញ?

**មាត្រា ១៧.- អត្រាការប្រាក់ដែលត្រូវបានកម្រិត ជាអាទិ៍**

១-អត្រាការប្រាក់ដែលត្រូវបានកម្រិត ដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥៨៥ (ការកម្រិតការប្រាក់) នៃក្រមរដ្ឋប្បវេណី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រឹមអត្រាចាប់ពី ១០ (ដប់) ភាគរយទៅ ៣០ (សាមសិប) ភាគរយក្នុង ១ (មួយ) ឆ្នាំ ។

២-ចំពោះការព្រមព្រៀងអំពីការកំណត់ជាមុននូវចំនួននៃសំណង ក្នុងករណីមិនអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ ប្រសិនបើផលចែកនៃចំនួនប្រាក់សំណងការខូចខាតដែលបានកំណត់មុន នោះជាមួយនឹងប្រាក់ដើម លើសពីអត្រាដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ភាគដែលលើសនោះត្រូវទុកជាមោឃៈ ។

៣-ប្រកាសខាងលើអាចកំណត់អត្រាដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើបាន ត្រឹមទំហំពី ១,២ ទៅ ២ ដង នៃអត្រាការប្រាក់ដែលត្រូវបានកម្រិត ដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ។

៤-កថាខណ្ឌទី ៣ និង កថាខណ្ឌទី ៤ នៃមាត្រា ៥៨៥ (ការកម្រិតការប្រាក់) នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីកូនបំណុលដែលបានបង់ផ្នែកលើស ដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើ ។

៥-បញ្ញត្តិនៃកថាខណ្ឌទី ២ និង កថាខណ្ឌទី ៤ ខាងលើ ត្រូវអនុវត្តចំពោះប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា ដោយចាត់ទុកថា ប្រាក់ធានានោះជាការកំណត់ជាមុននូវចំនួននៃសំណងក្នុងកម្រិតនៃការអនុវត្តបញ្ញត្តិនៃកថាខណ្ឌទី ២ និង កថាខណ្ឌទី ៤ ខាងលើនេះ ។

៦-ក្នុងករណីមិនមានការសន្យាពិសេសណាមួយស្តីពីប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ដែលភ្ជាប់ជាមួយនឹងការប្រាក់ បញ្ញត្តិនៃមាត្រានេះ និង មាត្រា ៥៨៥ (ការកម្រិតការប្រាក់) នៃក្រមរដ្ឋប្បវេណី ត្រូវអនុវត្តចំពោះប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវ ដោយចាត់ទុកថា ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវនោះជាការប្រាក់ ក្នុងកម្រិតនៃការអនុវត្តបញ្ញត្តិនៃមាត្រានេះ និង មាត្រា ៥៨៥ (ការកម្រិតការប្រាក់) នៃក្រមរដ្ឋប្បវេណីនោះ ។

# តើការប្រាក់យឺតយ៉ាវ (សំណងនៃការខូចខាត) ត្រូវកំណត់បែបណានៅពេលដែលម្ចាស់បំណុលប្តឹងទៅតុលាការទាមទារឱ្យកូនបំណុលសងប្រាក់វិញ? (បន្ត)

❖ ផ្អែកតាមមាត្រា ១៧ ខាងលើ មាន ២ ករណី៖

១-ករណីដែលភាគីបានព្រមព្រៀងគ្នាកំណត់ជាមុននូវសំណងខូចខាត ប្រាក់សំណងនេះត្រូវគិតជាអត្រាការប្រាក់ ដោយមិនឱ្យលើសពី ១,២ ទៅ ២ ដងនៃអត្រាការប្រាក់ដែលត្រូវបានកម្រិត (គឺយ៉ាងច្រើន ២៧%)

២-ករណីដែលមិនមានការសន្យាពិសេសនោះទេ មាត្រា ៥៨៥ ត្រូវអនុវត្តចំពោះប្រាក់សំណងនៃការខូចខាត ដោយចាត់ទុកថា ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវនោះ ជាការប្រាក់។ មានន័យថា ប្រាក់សំណងនៃការខូចខាត ត្រូវគិតតាមអត្រាការប្រាក់ដែលភាគីបានព្រមព្រៀងគ្នា។

❖ **មាន ៣ករណី ៖**

១-ភាគីបានព្រមព្រៀងគ្នាកំណត់អត្រានៃសំណងការខូចខាត (យកតាមកិច្ចសន្យា តែមិនឱ្យលើស ២៧%)

២-ភាគីមិនបានកំណត់អត្រានៃសំណងការខូចខាត តែបានកំណត់អត្រាការប្រាក់ក្នុងកិច្ចសន្យា (យកអត្រាក្នុងកិច្ចសន្យាជាអត្រានៃសំណងការខូចខាត)

៣-ភាគីមិនបានកំណត់អត្រាការប្រាក់ និងអត្រានៃសំណងការខូចខាត (យកអត្រាការប្រាក់តាមច្បាប់កំណត់ស្មើនឹង ៥% យោងតាមមាត្រា៥៨៥ និង មាត្រា៣១៨ នៃក្រមរដ្ឋប្បវេណី)

# តើអាចទាមទារសំណងជំងឺចិត្ត និងសំណងខូចខាតផ្សេងទៀតបន្ថែមលើការប្រាក់ឃើតយ៉ាវបានដែរឬទេ?

❖ កថាខណ្ឌទី២ នៃមាត្រា ៣៩៩ នៃក្រមរដ្ឋប្បវេណី (បញ្ញត្តិពិសេសអំពីកាតព្វកិច្ចសងជាប្រាក់)

២-ចំពោះការខូចខាតដែលមានចំនួនលើសពីការប្រាក់ក្នុងអំឡុងពេលនៃការឃើតយ៉ាវ ប្រសិនបើកូនបំណុលមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុសចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ នោះកូនបំណុលត្រូវរួចផុតពីការទទួលខុសត្រូវក្នុងការសងការខូចខាតនោះ។

❖ មាត្រា៤០០ នៃក្រមរដ្ឋប្បវេណី៖

១-ម្ចាស់បំណុលអាចទាមទារនូវសំណងនៃការខូចខាត គឺអាចទាមទារនូវសំណងនៃផលប្រយោជន៍ពីការអនុវត្តដែលខ្លួនត្រូវទទួលបានដោយកិច្ចសន្យានោះ ហើយក្រៅពីនេះ អាចទាមទារផងដែរនូវចំណាយដែលគ្មានប្រយោជន៍ដោយសារការមិនអនុវត្ត និងចំណាយ ឬបន្ទុកដែលបង្កើនឡើងដោយសារការមិនអនុវត្តកាតព្វកិច្ចក្នុងទំហំដែលមិនជាន់គ្នាជាមួយនឹងសំណងនៃផលប្រយោជន៍ពីការអនុវត្ត។

២-តុលាការក៏អាចបង្គាប់ឱ្យកូនបំណុលសងសំណងនៃការខូចខាតខាងផ្លូវចិត្ត ដោយផ្អែកលើការទាមទាររបស់ម្ចាស់បំណុលបានដែរ។ ចំពោះចំនួននៃសំណងនៃការខូចខាតខាងផ្លូវចិត្ត តុលាការត្រូវសម្រេចដោយគិតពិចារណាអំពីកាលៈទេសៈជុំវិញផ្សេងៗ។

# (៣)-តើកំណត់ប្រាក់ដើមនៅសល់ ឬគួរកំណត់ពីសិទ្ធិលើបំណុលសរុប ដែលកូនបំណុលត្រូវសងទៅម្ចាស់បំណុល?

## ការគណនាប្រាក់ដើមដែលនៅសល់

✓ កថាខណ្ឌទី៥ នៃមាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី

*៥-ចំពោះការអនុវត្តមាត្រានេះ នៅក្នុងករណីដែលចំនួនប្រាក់ដើមលើកិច្ចសន្យាខុសពីចំនួនទឹកប្រាក់នៃវត្ថុដែលអ្នកឱ្យខ្ចីបានប្រគល់ឱ្យជាក់ស្តែង ដូចជាករណីនៃការប្រគល់ប្រាក់ដើមដោយដកការប្រាក់ដែលត្រូវបង់នាពេលអនាគត ជាអាទិ៍ ចំនួនទឹកប្រាក់នៃវត្ថុដែលអ្នកឱ្យខ្ចីបានប្រគល់ដោយជាក់ស្តែងទៅឱ្យអ្នកខ្ចីនោះ ត្រូវទុកជាចំនួនប្រាក់ដើម។*

✓ កថាខណ្ឌទី៣ និងទី៤ នៃមាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី

៣-ភាគដែលលើសពីកម្រិតនៃអត្រាការប្រាក់ ត្រូវទុកជាមោឃៈ។

៤-នៅក្នុងករណីដែលបានសងការប្រាក់ដែលលើសពីអត្រាការប្រាក់ដែលបានកម្រិតហើយ ត្រូវចាត់ទុកថាភាគីដែលលើសនោះ ជាការកាត់បំណុលទៅលើប្រាក់ដើម។

✓ កថាខណ្ឌទី៣ និងទី៤ នៃមាត្រា ៥៨៥ នេះ ត្រូវយកទៅអនុវត្តដូចគ្នា ចំពោះករណីដែលកូនបំណុលបានបងប្រាក់សំណងខូចខាត (ការប្រាក់ឃឹតយ៉ាវ)។

## (៤)-តើតុលាការត្រូវពិនិត្យដោយឆន្ទានុសិទ្ធិ ចំពោះការយកភាគនៃការប្រាក់ និងភាគនៃការប្រាក់ឃើតយ៉ាវ ដែលបង់រួចលើសច្បាប់កំណត់ ទៅទូទាត់ជាមួយនឹងប្រាក់ដើមនៅសល់ មុននឹងសម្រេចអំពីប្រាក់ដើមដែរឬទេ?

❖ កថាខណ្ឌទី៤ នៃមាត្រា ៥៨៥ ក្រមរដ្ឋប្បវេណី

៤-នៅក្នុងករណីដែលបានសងការប្រាក់ដែលលើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិតហើយ ត្រូវចាត់ទុកថាភាគដែលលើសពីការកម្រិតនោះ ជាការកាត់បំណុលទៅលើប្រាក់ដើម។ នៅក្នុងករណីដែលបានកាត់បំណុលទៅលើប្រាក់ដើម ចំពោះផ្នែកដែលលើសកម្រិតហើយ តែនៅមានសល់ទៀត អ្នកឱ្យខ្ចីត្រូវសងទៅឱ្យអ្នកខ្ចីដោយភ្ជាប់ជាមួយនូវប្រាក់សំណងនៃការខូចខាត ដោយគណនាតាមអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ដោយគិតចាប់ពីថ្ងៃដែលបានបង្កើតឱ្យមានការសេសសល់នៃការសងរហូតដល់ថ្ងៃដែលបានសងនោះ។

❖ មាត្រា៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី (សិទ្ធិបំភ្លឺរបស់តុលាការ)

❖ មាត្រា ៣៥៧ នៃក្រមរដ្ឋប្បវេណី "ជនណាក៏អាចអះអាងអំពីមោឃភាពនៃកិច្ចសន្យាបានដែរ"

❖ មាត្រា១២៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី (ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ)

# ការគណនាប្រាក់ដើមដែលនៅសល់ (បន្ត)

- ✓ ដូច្នេះ ក្នុងការគណនាប្រាក់ដើមនៅសល់ ត្រូវយក ប្រាក់ដើមពិតប្រាកដ (កថាខណ្ឌទី ៥ នៃមាត្រា ៥៨៥) ដកចេញនូវការប្រាក់លើសការកម្រិតរបស់ច្បាប់ និងដកចេញប្រាក់សំណងខូចខាតដែលលើសអត្រាកម្រិតរបស់ច្បាប់ ។ (ប្រាក់ដើមក្នុងកិច្ចសន្យាខុសពីប្រាក់ដើមជាក់ស្តែងដែលម្ចាស់បំណុលប្រគល់ឱ្យកូនបំណុល)
- ✓ *ប្រាក់រង្វាន់ កម្រៃជើងសារ កម្រៃស៊ើបអង្កេត និងកម្រៃផ្សេងៗទៀតក៏ដោយ ត្រូវចាត់ទុកថាជាការប្រាក់ លើកលែងចំពោះសោហ៊ុយនៃការធ្វើកិច្ចសន្យា និងសោហ៊ុយនៃការសង (កថាខណ្ឌទី៦ នៃមាត្រា ៥៨៥)។*

# សម្មតិកម្មទី១

A បានឱ្យ B ខ្ចីប្រាក់ចំនួន ១ម៉ឺនដុល្លារ រយៈពេល ២ឆ្នាំ (១.១.២០២១-៣១.១២.២០២២), ដោយគ្មានការប្រាក់ និង គ្មានកំណត់អត្រាការប្រាក់ក្នុងអំឡុងពេលយឺតយ៉ាវនោះទេ។




**ចម្លើយ**

១)- A មិនអាចទាមទារការប្រាក់នោះទេ (មាត្រា៥៨៣ នៃក្រមរដ្ឋប្បវេណី)

២)- A អាចទាមទារការប្រាក់យឺតយ៉ាវ តាមអត្រាការប្រាក់ដែលច្បាប់កំណត់ (៥%) ដោយគិតចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ (មាត្រា៣៩៩ នៃក្រមរដ្ឋប្បវេណី)។

៣)- បន្ថែមលើសពីនេះ A អាចទាមទារសំណងការខូចខាតបន្ថែម ក្នុងលក្ខខណ្ឌដែលបានកំណត់ក្នុងកថាខណ្ឌទី២ មាត្រា៣៩៩ នៃក្រមរដ្ឋប្បវេណី (ត្រូវគណនាតាមការខូចខាតជាក់ស្តែង ហើយម្ចាស់បំណុលមានបន្ទុកក្នុងការបញ្ជាក់ដោយភស្តុតាងអំពីការខូចខាត - សរុបចំណុចទី២ និងចំណុចទី៣ មិនឱ្យលើសពី ២៧% ឡើយ)។

# សម្មតិកម្មទី២

A បានឱ្យ B ខ្ចីប្រាក់ចំនួន ១ម៉ឺនដុល្លារ រយៈពេល ២ឆ្នាំ (១.១.២០២១-៣១.១២.២០២២), មានការប្រាក់ ប៉ុន្តែមិនបានកំណត់អត្រាការប្រាក់ និង មិនបានកំណត់អត្រាការប្រាក់ក្នុងអំឡុងពេលយឺតយ៉ាវនោះទេ។




**ចម្លើយ**៖ ១)- A អាចទាមទារការប្រាក់ចំនួន ៥% (មាត្រា៥៨៣, មាត្រា៥៨៤ និងមាត្រា៣១៨ នៃក្រម)

២)- A អាចទាមទារការប្រាក់យឺតយ៉ាវ តាមអត្រាការប្រាក់ដែលច្បាប់កំណត់ (៥%) ដោយគិតចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ (កថាខណ្ឌទី៦ មាត្រា១៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី)។

៣)- បន្ថែមលើសពីនេះ A អាចទាមទារសំណងការខូចខាតបន្ថែម ក្នុងលក្ខខណ្ឌដែលបានកំណត់ក្នុងកថាខណ្ឌទី២ មាត្រា៣៩៨ នៃក្រមរដ្ឋប្បវេណី (ត្រូវគណនាតាមការខូចខាតជាក់ស្តែង ហើយម្ចាស់បំណុលមានបន្ទុកក្នុងការបញ្ជាក់ដោយភស្តុតាងអំពីការខូចខាត - សរុបចំណុចទី២ និងចំណុចទី៣ មិនឱ្យលើសពី ២៧% ឡើយ)។

# សម្មតិកម្មទី៣

A បានឱ្យ B ខ្ចីប្រាក់ចំនួន ១ម៉ឺនដុល្លារ រយៈពេល ២ឆ្នាំ (១.១.២០២១-៣១.១២.២០២២), ដោយកំណត់ការប្រាក់ ១៥% ក្នុងមួយឆ្នាំ និង គ្មានកំណត់អត្រាការប្រាក់ក្នុងអំឡុងពេលយឺតយ៉ាវនោះទេ។




ចម្លើយ

១)- A អាចទាមទារការប្រាក់បាន ១៥% ក្នុងមួយឆ្នាំ ចាប់ពី ១.១.២០២១ ដល់ឆ្នាំ ៣១.១២. ២០២២ (មាត្រា ៥៨៣ នៃក្រមរដ្ឋប្បវេណី)។

២)- A អាចទាមទារការប្រាក់យឺតយ៉ាវ តាមអត្រាការប្រាក់ ១៥% ក្នុងមួយឆ្នាំរហូតដល់សងគ្រប់ចំនួន ដោយគិតចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ រហូតដល់សងគ្រប់ចំនួន (មាត្រា១៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី)។

៣)-បន្ថែមលើសពីនេះ A អាចទាមទារសំណងការខូចខាតបន្ថែម ក្នុងលក្ខខណ្ឌដែលបានកំណត់ក្នុងកថាខណ្ឌទី២ មាត្រា៣៩៩ នៃក្រមរដ្ឋប្បវេណី (ត្រូវគណនាតាមការខូចខាតជាក់ស្តែង ហើយម្ចាស់បំណុលមានបន្ទុកក្នុងការបញ្ជាក់ដោយភស្តុតាងអំពីការខូចខាត - សរុបចំណុចទី២ និងចំណុចទី៣ មិនឱ្យលើសពី ២៧% ឡើយ)។

# សម្មតិកម្មទី៤

A បានឱ្យ B ខ្ចីប្រាក់ចំនួន ១ម៉ឺនដុល្លារ រយៈពេល ២ឆ្នាំ (១.១.២០២១-៣១.១២.២០២២), ដោយកំណត់អត្រាការប្រាក់ ១២% ក្នុងមួយឆ្នាំ និង កំណត់អត្រាការប្រាក់ក្នុងអំឡុងពេលយឺតយ៉ាវ ២៤% ក្នុងមួយឆ្នាំ។




## ចម្លើយ

១)- A អាចទាមទារការប្រាក់បាន ១២% ក្នុងមួយឆ្នាំចាប់ពីថ្ងៃទី១-១-២០២១ ដល់ ៣១-១២-២០២២

២)- A អាចទាមទារការប្រាក់យឺតយ៉ាវ តាមអត្រាការប្រាក់ ២៤% ក្នុងមួយឆ្នាំចាប់តាំងពីថ្ងៃទី ១-១-២០២៣ រហូតដល់សងគ្រប់ចំនួន (មាត្រា៤០៣ នៃក្រមរដ្ឋប្បវេណី និងមាត្រា១៧ នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី

# សម្មតិកម្មទី៥

A បានឱ្យ B ខ្ចីប្រាក់ចំនួន ១ម៉ឺនដុល្លារ រយៈពេល ២ឆ្នាំ (១.១.២០២១-៣១.១២.២០២២), ដោយកំណត់ការប្រាក់ ២៧% ក្នុងមួយឆ្នាំ និង គ្មានកំណត់អត្រាការប្រាក់ក្នុងអំឡុងពេលយឺតយ៉ាវនោះទេ។




ចម្លើយ

១)- A អាចទាមទារការប្រាក់ត្រឹម ១៨% ក្នុងមួយឆ្នាំ ចាប់ពី ១.១.២០២១ ដល់ឆ្នាំ ៣១.១២. ២០២២ ពីព្រោះផ្នែកដែលលើសត្រូវចាត់ទុកជាមោឃៈ (មាត្រា៥៨៥ នៃក្រមរដ្ឋប្បវេណី)។

២)- A អាចទាមទារការប្រាក់យឺតយ៉ាវ តាមអត្រាការប្រាក់ ១៨% ក្នុងមួយឆ្នាំរហូតដល់សងគ្រប់ចំនួន ដោយគិតចាប់ពីថ្ងៃទី ១.១.២០២៣ រហូតដល់សងគ្រប់ចំនួន (មាត្រា១៧ នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី)។

៣)-បន្ថែមលើសពីនេះ A អាចទាមទារសំណងការខូចខាតបន្ថែម ក្នុងលក្ខខណ្ឌដែលបានកំណត់ក្នុងកថាខណ្ឌទី២ មាត្រា៣៩៩ នៃក្រមរដ្ឋប្បវេណី (ត្រូវគណនាតាមការខូចខាតជាក់ស្ដែង ហើយម្ចាស់បំណុលមានបន្ទុកក្នុងការបញ្ជាក់ដោយភស្តុតាងអំពីការខូចខាត - សរុបចំណុចទី២ និងចំណុចទី៣ មិនឱ្យលើសពី ២៧% ឡើយ)។

# សម្មតិកម្មទី៦

A បានឱ្យ B ខ្ចីប្រាក់ចំនួន ១ម៉ឺនដុល្លារ រយៈពេល ២ឆ្នាំ (២០២១-២០២២), ដោយកំណត់ការប្រាក់ ១៨% ក្នុងមួយឆ្នាំ និង កំណត់ការប្រាក់យឺតយ៉ាវ ២៧% ក្នុងមួយឆ្នាំ និងមានការសន្យាពិសេសអំពីការបាត់បង់ផលប្រយោជន៍នៃកំណត់ពេល ហើយ B ត្រូវបង់ការប្រាក់រៀងរាល់ខែ ប៉ុន្តែ ឈប់បង់នៅខែទី១៣ ។




ចម្លើយ៖

១)- A អាចទាមទារការប្រាក់ចាប់ពីខែទី១៣ រហូតដល់កាលបរិច្ឆេទនៃការបាត់បង់ផលប្រយោជន៍នៃកាលកំណត់ពេល (មាត្រា ៣៣១ នៃក្រមរដ្ឋប្បវេណី)។ ចាប់ពីកាលបរិច្ឆេទនៃការបាត់បង់ផលប្រយោជន៍កំណត់ពេលទៅ លែងមានការប្រាក់កើតឡើង ហើយ (ករណីនេះ ការប្រាក់គិតត្រឹមខែទី១៨) ។

២)- ក្នុងករណីនេះ ការមិនអនុវត្តកាតព្វកិច្ចបង់ការប្រាក់យឺតយ៉ាវមាន ២ ដំណាក់កាលដូចខាងក្រោម៖

(ក)-ដំណាក់កាលខែទី១៣ ដល់ ខែទី១៨ ៖ តើអាចគណនា ២៧% នៃការប្រាក់ដែលខកខានរយៈពេល ៥ខែ រហូតដល់សងគ្រប់ចំនួនបានដែរឬទេ? តាមយោបល់ជំនាញការជប៉ុន ការប្រាក់ដែលខកខានប្រចាំខែមិនអាចយកមកជាមូលដ្ឋាននៃការគណនាការប្រាក់យឺតយ៉ាវ (សំណងនៃការខូចខាត) ទៀតបានឡើយ (មាត្រា៥៨៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)។

(ខ)-ដំណាក់កាលចាប់ពីខែទី១៨ ដល់ថ្ងៃសងគ្រប់ ៖ ត្រូវគណនា ២៧% នៃប្រាក់ដើមដែលនៅសល់ ដោយគិតចាប់ពីខែ

# សម្ពិតកម្មទី៧

A បានឱ្យ B ខ្ចីប្រាក់ចំនួន ១ម៉ឺនដុល្លារ រយៈពេល ២ឆ្នាំ (២០២១-២០២២), ដោយកំណត់ការប្រាក់ ១៨% ក្នុងមួយឆ្នាំ និង កំណត់ការប្រាក់យឺតយ៉ាវ ២៧% ក្នុងមួយឆ្នាំ និងមានការសន្យាពិសេសអំពីការបាត់បង់ផលប្រយោជន៍នៃកំណត់ពេល ហើយ B ត្រូវបង់រំលស់ប្រចាំខែ (មានប្រាក់ដើម និងការប្រាក់) ប៉ុន្តែ កូនបំណុលមិនបានបង់ប្រាក់ចាប់ពីខែទី៣ ។



LoanCalc 3/8

| No. | Payments | Principal | Interest | Balance |
| --- | --- | --- | --- | --- |
| 1 | 499 | 349 | 150 | 9,651 |
| 2 | 499 | 354 | 145 | 9,297 |
| 3 | 499 | 360 | 139 | 8,937 |
| 4 | 499 | 365 | 134 | 8,572 |
| 5 | 499 | 370 | 129 | 8,202 |
| 6 | 499 | 376 | 123 | 7,826 |
| 7 | 499 | 382 | 117 | 7,444 |
| 8 | 499 | 387 | 112 | 7,057 |
| 9 | 499 | 393 | 106 | 6,664 |
| 10 | 499 | 399 | 100 | 6,265 |
| 11 | 499 | 405 | 94 | 5,860 |
| 12 | 499 | 411 | 88 | 5,449 |
| 13 | 499 | 417 | 82 | 5,032 |
| 14 | 499 | 424 | 75 | 4,608 |
| 15 | 499 | 430 | 69 | 4,178 |
| 16 | 499 | 436 | 63 | 3,742 |
| 17 | 499 | 443 | 56 | 3,299 |
| 18 | 499 | 450 | 49 | 2,849 |
| 19 | 499 | 456 | 43 | 2,393 |
| 20 | 499 | 463 | 36 | 1,930 |
| 21 | 499 | 470 | 29 | 1,460 |
| 22 | 499 | 477 | 22 | 983 |
| 23 | 499 | 484 | 15 | 499 |
| 24 | 499 | 492 | 7 | 0 |
| Sum | 11,976 | | 1,983 | |

កាលកំណត់សងមកដល់

ចម្លើយ៖

១ )- A អាចទាមទារការប្រាក់ពីខែទី៤ រហូតដល់ខែទី៨។

២ )- A អាចទាមទារសំណងនៃការប្រាក់យឺតយ៉ាវ (សំណងការខូចខាត) ២ ដំណាក់កាលដូចខាងក្រោម ៖

(ក) ដំណាក់កាលទី១ ចាប់ពីខែទី៤ ដល់ខែទី៨ ៖ ២៧% នៃចំណែកប្រាក់ដើមប្រចាំខែ (ចំណែកនៃការប្រាក់ពុំអាចគណនាការប្រាក់យឺតយ៉ាវបានឡើយ)

-ប្រាក់ដើមខែទី៤ ចំនួន ៣៦៥$ ត្រូវគណនាការប្រាក់យឺតយ៉ាវ ចំនួន ៤ខែ។

-ប្រាក់ដើមខែទី៥ ចំនួន ៣៧០$ ត្រូវគណនាការប្រាក់យឺតយ៉ាវ ចំនួន ៣ខែ។

-ប្រាក់ដើមខែទី៦ ចំនួន ៣៧៦$ ត្រូវគណនាការប្រាក់យឺតយ៉ាវ ចំនួន ២ខែ។

-ប្រាក់ដើមខែទី៧ ចំនួន ៣៨២$ ត្រូវគណនាការប្រាក់យឺតយ៉ាវ ចំនួន ១ខែ។

-ប្រាក់ដើមខែទី៨ ចំនួន ៣៨៧$ ត្រូវក្លាយជាប្រាក់ដើមសរុបដែលនៅសល់ ហើយយកជាមូលដ្ឋាននៃគណនានៃកាលបរិច្ឆេទនៃកំណត់ពេលសងមកដល់។

(ខ) ដំណាក់កាលទី២ ចាប់ពីខែទី៩ រហូតដល់សងគ្រប់ចំនួន ស្មើនឹង ២៧% នៃប្រាក់ដើមនៅសល់សរុប។

# សម្ពុតិកម្មទី៨

A បានឱ្យ B ខ្ចីប្រាក់ចំនួន ១ម៉ឺនដុល្លារ រយៈពេល ២ឆ្នាំ (២០២១-២០២២), ដោយកំណត់ការប្រាក់ ១៨% ក្នុងមួយឆ្នាំ និង កំណត់ការប្រាក់យឺតយ៉ាវ ២៧% ក្នុងមួយឆ្នាំ ហើយ B ត្រូវបង់ការប្រាក់រៀងរាល់ខែ ប៉ុន្តែ ឈប់បង់នៅខែទី១៣ ។




ចម្លើយ៖

១)- A អាចទាមទារការប្រាក់ចាប់ពីខែទី១៣ រហូតដល់ថ្ងៃដែលត្រូវសងក្នុងកិច្ចសន្យានៅខែទី២៤ (មាត្រា៥៩១ នៃក្រមរដ្ឋប្បវេណី)

២)- ក្នុងករណីនេះ ការប្រាក់យឺតយ៉ាវមាន ២ដំណាក់កាលដូចខាងក្រោម៖

(ក)- ដំណាក់កាលខែទី១៣ដល់ខែទី២៤ ៖ តើអាចគណនា ២៧% នៃការប្រាក់ដែលខកខានចាប់ពីខែទី១៣ រហូតដល់ខែទី២៤ (១១ខែ) បានដែរឬទេ? តាមយោបល់ជំនាញការជប៉ុន ការប្រាក់ដែលខកខានប្រចាំខែមិនអាចយកមកជាមូលដ្ឋាននៃការគណនាការប្រាក់យឺតយ៉ាវ (សំណងនៃការខូចខាត) ទៀតបានឡើយ (មាត្រា៥៨៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី) ។

(ខ)- ដំណាក់កាលចាប់ពីខែទី២៤ រហូតដល់ថ្ងៃសងគ្រប់ចំនួន ៖ ត្រូវគណនា ២៧% នៃប្រាក់ដើមនៅសល់ដោយគិតចាប់ពីខែទី២៤ រហូតដល់សងគ្រប់ចំនួន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

**សំណុំរឿងរដ្ឋប្បវេណី**
សំណុំរឿងលេខ ២៦៩
ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣
សាលដីកាលេខ ៨៣ (ក)
ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤

# សាលដីកា

**ក្នុងនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈនៅថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៤។

ដោយក្រុមប្រឹក្សាជំនុំជម្រះ មានសមាសភាពដូចខាងក្រោម៖

១-ឯកឧត្តម **ជីវ កេង** ជាប្រធាន
២-ឯកឧត្តម **យស់ សុខឿន** ជាចៅក្រម
៣-ឯកឧត្តម **តែ សំអាង** ជាចៅក្រម
៤-ឯកឧត្តម **ជា សុខហៀង** ជាចៅក្រម
៥- ឯកឧត្តម **ម្លូច់ សំណាង** ជាចៅក្រម

**ចៅក្រមទទួលបញ្ជា**
ឯកឧត្តម **តែ សំអាង**

**ក្រឡាបញ្ជី**
លោក **ស៊ិន តារៈ**

**តំណាងមហាអយ្យការ**
ឯកឧត្តម **អ៊ុក គឹមសិទ្ធិ** ឋានៈជាអគ្គព្រះរាជអាជ្ញារង

**ដើមចោទ(ចុងបណ្ដឹងសាទុក្ខ)**

**ធនាគារ** ទីស្នាក់ការនៅ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ តំណាងដោយលោក កាន់លិខិតឆ្លងដែនលេខ

**អ្នកតំណាងដោយអាណត្តិ៖**លោកមេធាវី **អ៊ាង សូវសែន**

**សហចុងចម្លើយ(ដើមបណ្ដឹងសាទុក្ខ)**

១- **ក្រុមហ៊ុន** មានទីស្នាក់ការផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ តំណាងស្របច្បាប់ដោយឈ្មោះ **ទូច សុផល** កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០១៨២៧៧០ ចុះថ្ងៃទី





## សេចក្ដីសម្រេចបញ្ចប់

១.បដិសេធផ្នែកខ្លះនៃបណ្ដឹងសាទុក្ខលេខ ១៩៣ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣ របស់សហដើមបណ្ដឹងសាទុក្ខឈ្មោះ ឈ្មោះ និងឈ្មោះ ។

២.តម្កល់សាលដីកាលេខ **០៥ ក្រ.III.ដហ** ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣ របស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការ លើកលែងតែចំណុចតម្កល់ចំណុចទី៣ ទី៤ ទី៥ និងទី៦ នៃសេចក្ដីសម្រេចនៃសាលក្រមរដ្ឋប្បវេណីលេខ ៧៨៣ "ណ" ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ បដិសេធចោល ហើយសម្រេចជាថ្មី ដោយបង្គាប់ឲ្យសហដើមបណ្ដឹងសាទុក្ខឈ្មោះ

ឈ្មោះ និងឈ្មោះ បង់ការប្រាក់ និងការប្រាក់ពិន័យ ទៅឲ្យចុងបណ្ដឹងសាទុក្ខឈ្មោះ ធនាគារ ដូចខាងក្រោម៖

ក.បង់ការប្រាក់ចំនួន ៩,២៥ ភាគរយ ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ១០.៤០០.០០០.០០០ រៀល(ដប់ពាន់បួនរយលានរៀលគត់) គិតចាប់ពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ដល់ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២០។

ខ.បង់ការប្រាក់ចំនួន ៩,៥០ ភាគរយ ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ២៦៨.៩៧៨,៧៥ ដុល្លាអាមេរិក (ម្ភៃប្រាំមួយម៉ឺនប្រាំបីពាន់ប្រាំបួនរយចិតសិបប្រាំបីដុល្លារអាមេរិកនិងចិតសិបប្រាំសេន)គិតចាប់ពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ដល់ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២០។

គ.បង់ការប្រាក់ពិន័យចំនួន ២៥ភាគរយ ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ១០.៤០០.០០០.០០០ (ដប់ពាន់បួនរយលាន)រៀលគត់ គិតចាប់ពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ រហូតដល់ថ្ងៃសងប្រាក់ដើមគ្រប់ចំនួន។

ឃ.បង់ការប្រាក់ពិន័យចំនួន ២៥ ភាគរយ ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ២៦៨.៩៧៨,៧៥ (ម្ភៃប្រាំមួយម៉ឺនប្រាំបីពាន់ប្រាំបួនរយចិតសិបប្រាំបី ដុល្លារអាមេរិក និងចិតសិបប្រាំសេន) គិតចាប់ពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ រហូតដល់ថ្ងៃសងប្រាក់ដើមគ្រប់ចំនួន។

ច្រានចោលការទាមទាររបស់ដើមចោទលើសពីនេះ។

៣.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ "ចុងបណ្ដឹងសាទុក្ខ" និងសហចុងចម្លើយ "សហដើមបណ្ដឹងសាទុក្ខ"។

# ៤-ការសន្និដ្ឋានរួម និងសំណើសុំការសម្រេច

១-អាចសម្រេចអំពីការប្រាក់ លុះត្រាតែមានកំណត់ក្នុងកិច្ចសន្យា។ បើមិនបានកំណត់អត្រាក្នុងកិច្ចសន្យា គឺយកតែ ៥%។ បើបានកំណត់អាត្រាក្នុងកិច្ចសន្យា អត្រាការប្រាក់ខ្ពស់បំផុតក្នុងកិច្ចសន្យាគឺត្រឹមតែ ១៨% ក្នុងមួយឆ្នាំ។ ភាគដែលលើសពី ១៨% ក្នុងមួយឆ្នាំ ត្រូវទុកជាមោឃៈ។ កូនបំណុលមានសិទ្ធិទាមទារឱ្យកាត់ចេញពីប្រាក់ដើមនូវភាគនៃការប្រាក់ដែលលើសពីច្បាប់កំណត់ និងបានបង់រួចទៅឱ្យម្ចាស់បំណុល។

២-ការប្រាក់យឺតយ៉ាវ ជាសំណងនៃការខូចខាត។ បើបានកំណត់ក្នុងកិច្ចសន្យា គឺមានអត្រាខ្ពស់បំផុតត្រឹម ២៧% ក្នុងមួយឆ្នាំ។ ភាគដែលលើសពី ២៧% ក្នុងមួយឆ្នាំ ត្រូវទុកជាមោឃៈ។ តែបើមិនបានកំណត់ក្នុងកិច្ចសន្យាទេ ប្រាក់សំណងនៃការខូចខាត ត្រូវយកតាមអត្រាការប្រាក់ដែលបានព្រមព្រៀងក្នុងកិច្ចសន្យា (មិនលើសពី ១៨% ក្នុងមួយឆ្នាំ) ឬតាមអត្រាការប្រាក់ដែលច្បាប់បានកំណត់ (៥% ក្នុងមួយឆ្នាំ) ក្នុងករណីដែលក្នុងកិច្ចសន្យាមិនបានកំណត់អំពីអត្រាការប្រាក់។ កូនបំណុលមានសិទ្ធិទាមទារឱ្យកាត់ចេញពីប្រាក់ដើមនូវដែលភាគនៃការប្រាក់យឺតយ៉ាវដែលលើសពីច្បាប់កំណត់ និងបានបង់រួចទៅឱ្យម្ចាស់បំណុល។

# ការសន្និដ្ឋានរួម និងសំណើសុំការសម្រេច (ត)

៣-ការប្រាក់ អាចសម្រេចផ្តល់ឱ្យតែសម្រាប់អំឡុងពេលនៃកិច្ចសន្យា ឬត្រឹមថ្ងៃកាលកំណត់សងបានមកដល់ (ការបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល) ។ ចាប់ពីពេលបាត់បង់ផលប្រយោជន៍នៃការកំណត់ពេលទៅ មិនមានការប្រាក់ទៀតទេ។

៤-ការប្រាក់យឺតយ៉ាវជា គឺការកំណត់ជាមុននូវសំណងការខូចខាត។

- គួរប្តូរពីការប្រើពាក្យ ការប្រាក់យឺតយ៉ាវ មកជា "សងសំណងនៃការខូចខាត"។
- សំណងនៃការខូចខាតនេះ ត្រូវគិតជា អត្រា។
- សំណងនៃការខូចខាត អាចមានទាំងសម្រាប់ប្រាក់ដើមដែលត្រូវបង់ក្នុងអំឡុងពេលនៃកិច្ចសន្យា និងទាំងសម្រាប់ប្រាក់ដើមនៅសល់ដែលត្រូវបង់ក្រោយពេលកំណត់សងមកដល់
- សំណងនៃការខូចខាតចាប់ពីកាលកំណត់សងមកដល់ អាចគណនារហូតដល់ថ្ងៃសងរួច ដោយផ្អែកលើមូលដ្ឋាននៃប្រាក់ដើមដែលនៅសល់។
- អត្រានៃសំណងការខូចខាតមាន ៣ ករណី៖

(១)-បើភាគីបានព្រមព្រៀងគ្នាកំណត់អត្រានៃសំណងការខូចខាត (យកតាមកិច្ចសន្យា),

(២)-បើភាគីមិនបានកំណត់អត្រានៃសំណងការខូចខាត តែភាគីបានកំណត់អត្រាការប្រាក់ក្នុងកិច្ចសន្យា (យកអត្រាក្នុងកិច្ចសន្យាជាអត្រានៃសំណងការខូចខាត) និង

(៣)-បើភាគីមិនបានកំណត់ទាំងអត្រាការប្រាក់ ទាំងអត្រានៃសំណងការខូចខាត (យកអត្រាការប្រាក់តាមច្បាប់កំណត់ស្មើនឹង ៥% យោងតាមមាត្រា៥៨៥ និង មាត្រា៣១៨ នៃក្រមរដ្ឋប្បវេណី)

# ការសន្និដ្ឋានរួម និងសំណើសុំការសម្រេច (ត)

## ៥-ការសម្រេចអំពីសំណងនៃការខូចខាតផ្សេងទៀត

❖ ករណីទី១៖ បើអត្រានៃសំណងនៃការខូចខាតគិតត្រឹមអត្រា ៥% ដែលច្បាប់កំណត់ ម្ចាស់បំណុលអាចទាមទារសំណងនៃរការខូចខាតបន្ថែម ក្នុងលក្ខខណ្ឌដែលបានកំណត់ក្នុងកថាខណ្ឌទី២ មាត្រា៣៩៩ នៃក្រមរដ្ឋប្បវេណី (ត្រូវគណនាតាមការខូចខាតជាក់ស្តែង ហើយម្ចាស់បំណុលមានបន្ទុកក្នុងការបញ្ជាក់ដោយភស្តុតាងអំពីការខូចខាត មិនឱ្យលើសពី ២៧% ឡើយ)

❖ ករណីទី២៖ បើអត្រានៃសំណងនៃការខូចខាតយកតាមអត្រាការប្រាក់ដែលបានព្រមព្រៀង ម្ចាស់បំណុលអាចទាមទារសំណងនៃការខូចខាតបន្ថែម ក្នុងលក្ខខណ្ឌដែលបានកំណត់ក្នុងកថាខណ្ឌទី២ មាត្រា៣៩៩ នៃក្រមរដ្ឋប្បវេណី (ត្រូវគណនាតាមការខូចខាតជាក់ស្តែង ហើយម្ចាស់បំណុលមានបន្ទុកក្នុងការបញ្ជាក់ដោយភស្តុតាងអំពីការខូចខាត មិនឱ្យលើសពី ២៧% ឡើយ)

❖ ករណីទី៣៖ បើអត្រានៃសំណងនៃការខូចខាតត្រូវបានកំណត់ក្នុងកិច្ចសន្យាមានចំនួនតិចហួសហេតុពេក ចៅក្រមអាចពិចារណាសំណងបន្ថែមដោយពិចារណាលើមាត្រា៤០៣ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ប្រសិនបើមានការទាមទារពីភាគី។

# ការសន្និដ្ឋានរួម និងសំណើសុំការសម្រេច (ត)

៦-ក្នុងអំឡុងពេលនៃការអនុវត្តកិច្ចសន្យា សំណងនៃការខូចខាតអាចគណនាបានចំពោះតែចំណែកនៃប្រាក់ដើមប្រចាំខែដែលខកខានប៉ុណ្ណោះ រហូតដល់ត្រឹមកាលកំណត់សងមកដល់ (មិនអាចគណនាចំណែកនៃការប្រាក់បានទេ)។ សំណងនៃការខូចខាតក្រោយកាលកំណត់សងមកដល់ ត្រូវគណនាដោយផ្អែកលើប្រាក់ដើមដែលនៅសល់ រហូតដល់ថ្ងៃសងរួច។

៧-ក្នុងការគណនាប្រាក់ដើមនៅសល់ ចៅក្រមគួរប្រើធន្ទានុសិទ្ធិ និងសិទ្ធិបំភ្លឺ ដើម្បីកាត់កងការប្រាក់បង់លើស និងសំណងនៃការខូចខាតដែលបង់លើស ពីប្រាក់ដើម មុននឹងកំណត់ប្រាក់ដើមនៅសល់ និងអនុវត្តស្របតាមមាត្រា៥៨៥ កថាខណ្ឌទី៣, ទី៥ និងទី៦ នៃក្រមរដ្ឋប្បវេណី និងមាត្រា១៧ កថាខណ្ឌទី៤ នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី (ជាបញ្ញត្តិអនុវត្តដោយបង្ខំដែលចៅក្រមត្រូវប្រើប្រាស់ធន្ទានុសិទ្ធិក្នុងការសម្រេច)។

*(កថាខណ្ឌទី៤ នៃមាត្រា ៥៨៥ ក្រមរដ្ឋប្បវេណី៖ នៅក្នុងករណីដែលបានសងការប្រាក់ដែលលើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិតហើយ ត្រូវចាត់ទុកថាភាគដែលលើសពីការកម្រិតនោះ ជាការកាត់បំណុលទៅលើប្រាក់ដើម។ នៅក្នុងករណីដែលបានកាត់បំណុលទៅលើប្រាក់ដើមចំពោះផ្នែកដែលលើសកម្រិតហើយ តែនៅមានសល់ទៀត អ្នកឱ្យខ្ចីត្រូវសងទៅឱ្យអ្នកខ្ចីដោយភ្ជាប់ជាមួយនូវប្រាក់សំណងនៃការខូចខាត ដោយគណនាតាមអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ដោយគិតចាប់ពីថ្ងៃដែលបានបង្កើតឱ្យមានការសេសសល់នៃការសងរហូតដល់ថ្ងៃដែលបានសងនោះ។)*

៨-ស្នើកែសម្រួលប្រកាសស្ដីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត (២១/១២/២០១១)។



# សូមអរគុណ!